# ខុទ្ទកវត្ថុខន្ធកៈ

## បាលី~ប្រែ



រៀបចំដោយ

ភិក្ខុវិមលោ សាន ថាវីន

# ខុទ្ទកបក្កុក្នុនកៈ

## បាលី~ប្រែ

ប្រមូលរៀបរៀងដោយ
**ភិក្ខុវិមលោ សាន ថាវីន**
**ព.ស.២៥៦៣**

សៀវភៅឈ្មោះ **ខុទ្ទកវត្ថុខន្ធកៈ** បាលី-ប្រែ
រៀបរៀងដោយ ភិក្ខុ វិមលោ សាន ថាវីន
ពិនិត្យដោយ សា. ចៅ ដាលី (សមណសិស្ស)
សា. រ៉ឹម រ័ត្ន (សមណសិស្ស)
ទីកន្លែងធ្វើ វត្តកច្ឆបបពិត "ភ្នំអណ្ដើក"
ភូមិក្រពើជើង ឃុំភ្នំសំពៅ ស្រុកបាណន់
ខេត្តបាត់ដំបង
កាលបរិច្ឆេទ ក្នុងពុទ្ធស័ករាជ ២៥៦៣

ធម្មប្រទីប Dhammapadīpa


សមណសិស្សថ្នាក់វិន័យបឋមសិក្សា ព.ស.២៥៦៣


ភិក្ខុវិមលោ សាន ថាវីន

# អារម្ភកថា

កូនសៀវភៅដែលអ្នកកំពុងតែកាន់នេះ វាមិនមែនជាសៀវភៅដែលមានពាក្យអធិប្បាយអំពីន័យសេចក្តីឱ្យបានទូលំទូលាយដូចជាគម្ពីរអដ្ឋកថា និងដីកាទេ គ្រាន់តែជាសៀវភៅដែលដកស្រង់យកនូវពុទ្ធប្បញ្ញត្តិដែលសំខាន់ ៗ ក្នុងការយកមកប្រតិបត្តិប្រចាំថ្ងៃ របស់បព្វជិតដែលបួស-ថ្មីបានចូលមកសិក្សាព្រះវិន័យថ្នាក់បឋមសិក្សាប៉ុណ្ណោះ។

គោលបំណងដែលខ្ញុំធ្វើសៀវភៅនេះឡើង គឺ៖

១.ដើម្បីងាយស្រួលក្នុងការកាន់ទន្ទេញ ព្រោះសៀវ-ភៅនេះមានទំហំ និងកម្រាស់តូចល្មមងាយស្រួលក្នុងការទុកដាក់ សូម្បីតែពេលបិណ្ឌបាត ក៏អាចយកមកទន្ទេញបានដែរ ។

២.សៀវភៅនេះមានពុម្ពអក្សរ (Font) ស្រួលមើលពិសេសសម្រាប់សាមណេរតូចៗ ។

ខ្ញុំសង្ឃឹមថា កូនសៀវភៅតូចនេះ នឹងបានជាដៃគូរសម្រាប់សមណសិស្សកំពុងសិក្សាក្នុងខុទ្ទកវត្ថុក្ខន្ធកៈនេះ ជាអ្នកប្រាថ្នាទ្រទ្រង់នូវព្រះធម៌វិន័យ ព្យាយាមទន្ទេញ

និងទ្រទ្រង់នូវចាំទុកនូវពុទ្ធប្បញ្ញត្តិ និងអនុញ្ញាតដែលព្រះ ដ៏មានព្រះភាគទ្រង់បានត្រាស់សម្តែងដោយល្អ ដើម្បីជាមូលដ្ឋានក្នុងការយកមកប្រតិបត្តិឱ្យក្លាយទៅជា សាវ័កដ៏ល្អក្នុងព្រះពុទ្ធសាសនាតរៀងទៅ ។

ដោយអំណាចនៃបុណ្យកុសលថ្នាក់ធម្មទាននេះ សូមឱ្យព្រះធម៌វិន័យ ប្រតិស្ឋានក្នុងដួងហឫទ័យរបស់កុល-បុត្រគ្រប់រូបដែលចេញចាកផ្ទះ មកបួសក្នុងព្រះពុទ្ធសា-សនានេះជាអ្នកប្រតិបត្តិឱ្យបានល្អខ្ជាប់ខ្ជួនតរៀងទៅ ។

**វិនយោ សាសនស្ស មូលំ**

វិន័យជាឫសគល់នៃព្រះពុទ្ធសាសនា

---------

ថ្ងៃ ១៣ កើត ខែ ស្រាពណ៍ ព.ស.២៥៦៣

ត្រូវនឹងថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៩

**ភិក្ខុ វិមលោ សាន ចាវីន**

# សន្លឹកប្រាប់មាតិកា

១.សិក្ខាបទបញ្ញត្តិចំពោះការងូតទឹក............................១
២.មិនត្រូវទ្រទ្រង់គ្រឿងប្រដាប់........................................ ៣
៣.មិនត្រូវទុកសក់វែងជាដើម..........................................៤
៤.ភិក្ខុមិនត្រូវមើលមុខនិមិត្តជាដើម ..............................៥
៥.ភិក្ខុមិនត្រូវទៅមើលរាំជាដើម ....................................៧
៦.ទោស ៥ ប្រការមានដល់ភិក្ខុច្រៀងធម៌ ........................៧
៧.សំពត់រោមសត្វ ...........................................................៨
៨.បញ្ញត្តិចំពោះផ្លែស្វាយ ....................................................៩
៩.សមណកប្ប ៥ យ៉ាង......................................................៩
១០.មេត្តាដើម្បីខ្លួន............................................................ ១០
១១.ការកាត់អង្គជាត ......................................................... ១០
១២.បាត្រ ១១ យ៉ាងភិក្ខុមិនគួរប្រើប្រាស់...........................១១
១៣.ទ្រង់អនុញ្ញាតបាត្រ.....................................................១១
១៤.ទ្រង់អនុញ្ញាតជើងបាត្រ..............................................១២
១៥.ជើងបាត្រ ៣ យ៉ាង.......................................................១២
១៦.ការទុកដាក់បាត្រ .........................................................១៣

១៧.ទ្រង់អនុញ្ញាតទីសម្រាប់ទុកបាត្រ ........................ ១៥
១៨.កាកអាមិស............................................១៨
១៩.សំពត់តម្រងទឹក ........................................ ១៩
២០.អនុញ្ញាតមុង...........................................២០
២១.ភិក្ខុអាក្រាត .........................................២១
២២.ទីបិទបាំង ៣ យ៉ាង...................................២២
២៣.និសីទនៈជាដើម ......................................២២
២៤.ភាជន៍ពិសេសជាដើម .................................. ២៤
២៥.ឯកភាជនេជាដើម ...................................... ២៤
២៦.ការផ្កាប់បាត្រដល់វឌ្ឍលិច្ឆវី ............................ ២៥
២៧.កម្រាលនិងទ្រនាប់សម្រាប់ជូតជើង.....................២៧
២៨.ផ្តិត................................................... ២៩
២៩.ឆត្រ...................................................៣០
៣០.ឈើច្រត់ជាដើម.........................................៣១
៣១.ភិក្ខុអ្នកទំពាអៀង.....................................៣១
៣២.ការរើសគ្រាប់បាយ .....................................៣២
៣៣.មិនត្រូវទុកក្រចកវែង ................................ ៣៣

៣៤.មិនត្រូវឱ្យគេកាត់ពុកមាត់-សក់..........................៣៤
៣៥.ចង្កៀលអាចម៍ត្រចៀកជាដើម............................៣៦
៣៦.កាយពន្ធ ..................................................៣៨
៣៧.ឡេវនិងអន្ទាក់ឡេវចីវរ ....................................៤០
៣៨.ភិក្ខុមិនត្រូវស្លៀកនិងដណ្ដប់ដូចគ្រហស្ថ ............... ៤២
៣៩.ភិក្ខុមិនត្រូវនាំអម្រែកទេ ................................៤៣
៤០.ឈើស្ទន់ ....................................................៤៣
៤១.ភិក្ខុដុតព្រៃ ..................................................៤៥
៤២.ការឡើងដើមឈើ.............................................៤៦
៤៣.រៀនពុទ្ធវចនៈតាមសកភាសា...............................៤៦
៤៤.លោកាយតៈ.................................................. ៤៧
៤៥.កណ្ដាស..................................................... ៤៨
៤៦.ការបន្ទោបង់បស្សាវៈ និងវច្ចៈ ...............................៤៩

# ខុទ្ទកវត្ថុខន្ធកៈ

## ១.សិក្ខាបទបញ្ញត្តិចំពោះការងូតទឹក

១. ន ភិក្ខវេ នហាយមានេន ភិក្ខុនា រុក្ខេ កាយោ ឧគ្ឃំសេតព្វោ យោ ឧគ្ឃំសេយ្យ អាបត្តិ ទុក្កដស្ស ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុងូតទឹកមិនត្រូវត្រដុសកាយនឹងដើមឈើទេ ភិក្ខុណាត្រដុស ត្រូវអាបត្តិទុក្កដ ។

២. ន ភិក្ខវេ នហាយមានេន ភិក្ខុនា ថម្ភេ កាយោ ឧគ្ឃំសេតព្វោ យោ ឧគ្ឃំសេយ្យ អាបត្តិ ទុក្កដស្ស ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុងូតទឹកមិនត្រូវត្រដុសកាយនឹងសសរទេ ភិក្ខុណាត្រដុស ត្រូវអាបត្តិទុក្កដ ។

៣. ន ភិក្ខវេ នហាយមានេន ភិក្ខុនា កុឌ្ឌេ កាយោ ឧគ្ឃំសេតព្វោ យោ ឧគ្ឃំសេយ្យ អាបត្តិ ទុក្កដស្ស ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុងូតទឹក មិនត្រូវត្រដុសកាយនឹងជញ្ជាំងទេ ភិក្ខុណាត្រដុស ត្រូវអាបត្តិទុក្កដ ។

**៤. ន ភិក្ខវេ នហាយមានេន អដ្ឋានេ នហាយិតព្វំ យោ នហាយេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុកាលងូតទឹក មិនត្រូវងូតក្នុងទីមិនគួរទេ ភិក្ខុណាងូត ត្រូវអាបត្តិទុក្កដ ។

**៥. ន ភិក្ខវេ គន្ធព្វហត្ថកេន នហាយិតព្វំ យោ នហាយេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុ មិនត្រូវងូតទឹកដោយឈើដែលគេធ្វើជាដៃគន្ធព្វទេ ភិក្ខុណាងូត ត្រូវអាបត្តិទុក្កដ ។

**៦. ន ភិក្ខវេ កុរុវិន្ទកសុត្តិយា នហាយិតព្វំ យោ នហាយេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវងូតទឹក ដោយដុំលំអិតថ្មឈ្មោះកុរុវិន្ទកៈឡើយ ភិក្ខុណាងូត ត្រូវអាបត្តិទុក្កដ ។

**៧. ន ភិក្ខវេ វិគ្គយ្ហ បរិកម្មំ ការាបេតព្វំ យោ ការា-បេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវញ៉ាំង គ្នានឹងគ្នាឱ្យធ្វើបរិកម្មទៅវិញទៅមកទេ ភិក្ខុណាឱ្យធ្វើ ត្រូវអាបត្តិទុក្កដ ។

**៨. ន ភិក្ខវេ មល្លកេន នហាយិតព្វំ យោ នហាយេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវងូតទឹក ដោយឈើមានសណ្ឋានដូចជើងកន្ធោរទេ ភិក្ខុណាងូត ត្រូវអាបត្តិទុក្កដ ។

**៩. អនុជានាមិ ភិក្ខវេ គិលានស្ស អកតមល្លកំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឈើមានសណ្ឋានដូចជើងកន្ធោរ ដែលគេមិនបានឆ្លាក់ជាក្បាច់ធ្មេញមករ ដល់ភិក្ខុមានជម្ងឺ ។

**១០. អនុជានាមិ ភិក្ខវេ ឧក្កាសិកំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតខ្នាញ់សំពត់ (សម្រាប់ភិក្ខុចាស់ជរាងូតទឹកដុសខ្លួនបាន) ។

**១១. អនុជានាមិ ភិក្ខវេ បុថុបាណិកំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតការដុសខ្នងដោយដៃបាន ។

## ២.មិនត្រូវទ្រទ្រង់គ្រឿងប្រដាប់

**១២. ន ភិក្ខវេ វល្លិកំ ធារេតព្វំ, ន បាមង្គំ ធារេតព្វំ,**

**ន កណ្ឋសុត្តកំ ធារេតព្វំ, ន កដិសុត្តកំ ធារេតព្វំ, ន ឱវដ្ដិកំ ធារេតព្វំ, ន កាយុរំ ធារេតព្វំ, ន ហត្ថាភរណំ ធារេតព្វំ, ន អង្គុលិមុទ្ទិកំ ធារេតព្វំ យោ ធារេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទ្រទ្រង់គ្រឿងប្រដាប់ត្រចៀក, មិនត្រូវទ្រទ្រង់សង្វារ, មិនត្រូវទ្រទ្រង់គ្រឿងប្រដាប់ក, មិនត្រូវទ្រទ្រង់គ្រឿងប្រដាប់ចង្កេះ, មិនត្រូវពាក់កង, មិនត្រូវទ្រទ្រង់គ្រឿងប្រដាប់ដើមដៃ, មិនត្រូវទ្រទ្រង់គ្រឿងប្រដាប់ដៃ, មិនត្រូវពាក់ចិញ្ចៀន ភិក្ខុណាទ្រទ្រង់ ត្រូវអាបត្តិទុក្កដ ។

## ៣.មិនត្រូវទុកសក់វែងជាដើម

**១៣. ន ភិក្ខវេ ទីឃា កេសា ធារេតព្វា យោ ធារេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទុកសក់វែងទេ ភិក្ខុណាទុក ត្រូវអាបត្តិទុក្កដ ។

**១៤.អនុជានាមិ ភិក្ខវេ ទុមាសិកំ វា ទុវង្គុលំ វា ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យទុកសក់កំណាត់

កាលត្រឹមពីរខែ ឬកំណត់ត្រឹមពីរធ្នាប់ ។

១៥. ន ភិក្ខវេ កោច្ឆេន កេសា ឱសណ្ហេតព្វា, ន ផណកេន កេសា ឱសណ្ហេតព្វា, ន ហត្ថផណកេន កេសា ឱសណ្ហេតព្វា, ន សិត្ថតេលកេន កេសា ឱសណ្ហេតព្វា, ន ឧទកតេលកេន កេសា ឱសណ្ហេតព្វា យោ ឱសណ្ហេយ្យ អាបត្តិ ទុក្កដស្ស ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវសិតសក់ដោយស្និត, មិនត្រូវសិតសក់ដោយក្រាស, មិនត្រូវជ្រងសក់ដោយដៃធ្វើជាក្រាស, មិនត្រូវសិតសក់ដោយក្រមួននិងប្រេង, មិនត្រូវ សិតសក់ដោយប្រេងដែលលាយដោយទឹកទេ ភិក្ខុណាសិត ត្រូវអាបត្តិទុក្កដ ។

## ៤.ភិក្ខុមិនត្រូវមើលមុខនិមិត្តជាដើម

១៦.ន ភិក្ខវេ អាទាសេ វា ឧទកបត្តេ វា មុខនិមិត្តំ ឱលោកេតព្វំ យោ ឱលោកេយ្យ អាបត្តិ ទុក្កដស្ស។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវមើលមុខនិមិត្តក្នុង

កញ្ចក់ ឬក្នុងភាជនៈទឹកទេ ភិក្ខុណាមើល ត្រូវអាបត្តិទុក្កដ ។

**១៧. អនុជានាមិ ភិក្ខវេ អាពាធប្បច្ចយា អាទាសេ វា ឧទកបត្តេ វា មុខនិមិត្តំ ឱលោកេតុំ ។** ម្នាលភិក្ខុទាំងឡាយ បើមានអាពាធជាហេតុ តថាគតអនុញ្ញាតឱ្យភិក្ខុមើលមុខនិមិត្ត ក្នុងកញ្ចក់ ឬក្នុងភាជនៈទឹកបាន ។

**១៨. ន ភិក្ខវេ មុខំ អាលិម្បិតព្វំ, ន មុខំ ឧម្មទ្ទិតព្វំ, ន មុខំ ចុណ្ណេតព្វំ, ន មនោសិលកាយ មុខំ លញ្ឆេតព្វំ, ន អង្គរាគោ កាតព្វោ, ន មុខរាគោ កាតព្វោ, ន អង្គរាគមុខរាគោ កាតព្វោ យោ ករេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវផាត់មុខ, មិនត្រូវដុសខាត់មុខ, មិនត្រូវប្រស់មុខ, មិនត្រូវចុចមុខដោយថ្នមនោសិលា, មិនត្រូវធ្វើការលាបខ្លួន, មិនត្រូវធ្វើការលាបមុខ, មិនត្រូវធ្វើការលាបទាំងខ្លួនទាំងមុខទេ ភិក្ខុណាធ្វើ ត្រូវអាបត្តិទុក្កដ ។

**១៩. អនុជានាមិ ភិក្ខវេ អាពាធប្បច្ចយា មុខំ**

**អាលិម្បិតុំ ។** ម្នាលភិក្ខុទាំងឡាយ បើមានអាពាធជាហេតុ តថាគតអនុញ្ញាតឱ្យភិក្ខុផាត់មុខបាន ។

## ៥.ភិក្ខុមិនត្រូវទៅមើលរាំជាដើម

២០. **ន ភិក្ខវេ នច្ចំ វា គីតំ វា វាទិតំ វា ទស្សនាយ គន្តព្វំ យោ គច្ឆេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទៅមើលរាំ ស្តាប់ច្រៀង ឬភ្លេងប្រគំទេ ភិក្ខុណាទៅ ត្រូវអាបត្តិទុក្កដ ។

## ៦.ទោស ៥ ប្រការមានដល់ភិក្ខុច្រៀងធម៌

១. **អត្តនោបិ តស្មឹ សរេ សារជ្ជតិ** ភិក្ខុនោះត្រេកអរក្នុងសំឡេងរបស់ខ្លួននោះ ។

២. **បរេបិ តស្មឹ សរេ សារជ្ជន្តិ** ជនទាំងឡាយដទៃរមែងត្រេកអរក្នុងសំឡេងនោះ ។

៣. **គហបតិកាបិ ឧជ្ឈាយន្តិ** គហបតីទាំងឡាយតែងពោលទោស ។

**៤. សរកុត្តិម្បិ និកាមយមានស្ស សមាធិស្ស ភង្គោ ហោតិ** បុគ្គលដែលពេញចិត្តនឹងការសូត្ររលាក់រលែក សំឡេងរមែងខូចសមាធិ ។

**៥. បច្ឆិមា ជនតា ទិដ្ឋានុគតឹ អាបជ្ជតិ** ពួកជនខាងក្រោយនឹងដល់នូវទិដ្ឋានុគតិ (យកតម្រាប់តាម) ។

**២១. ន ភិក្ខវេ អាយតកេន គីតស្សរេន ធម្មោ គាយិតព្វោ យោ គាយេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវច្រៀងធម៌ដោយសំឡេងច្រៀងដ៏វែងៗ ទេ ភិក្ខុណាច្រៀង ត្រូវអាបត្តិទុក្កដ ។

**២២. អនុជានាមិ ភិក្ខវេ សរភញ្ញំ ។** ម្នាលភិក្ខុទាំង-ឡាយ តថាគតអនុញ្ញាតឱ្យសូត្រសរភញ្ញបាន ។

## ៧.សំពត់រោមសត្វ

**២៣. ន ភិក្ខវ ពាហិរលោមី ឧណ្ណី ធារេតព្វា យោ ធារេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុ មិនត្រូវប្រើប្រាស់សំពត់ដែលគេធ្វើដោយ រោមសត្វ

មានរោមចេញមកខាងក្រៅទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។

## ៨.បញ្ញត្តិចំពោះផ្លែស្វាយ

**២៨. ន ភិក្ខវេ អម្ពំ បរិភុញ្ជិតព្វំ យោ បរិភុញ្ជេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់ផ្លែស្វាយទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ ។

**២៩. បដិគ្គណ្ហថ ភិក្ខវេ បរិភុញ្ជថ ។ អនុជានាមិ ភិក្ខវេ អម្ពបេសិកំ ។** ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរទទួលឆាន់ចុះ ម្នាលភិក្ខុទាំងឡាយតថាគតអនុញ្ញាតចំណិតផ្លែស្វាយ ។

## ៩.សមណកប្ប ៥ យ៉ាង

**១.អគ្គិបរិចិតំ**[១] ផ្លែឈើដែលគេសម្រេចដោយភ្លើង
**២.សត្ថបរិចិតំ** ផ្លែឈើដែលគេសម្រេចដោយសស្ត្រា
**៣.នខបរិចិតំ** ផ្លែឈើដែលគេសម្រេចដោយក្រចក

[១] បញ្ចហិ សមណកប្បេហិ ផលំ បរិភុញ្ជិតុំ អគ្គិបរិជិតំ សត្ថបរិជិតំ នខបរិជិតំ អពីជំ និព្វដ្ដពីជមេវ បញ្ចមន្តិ។ (បាចិត្តិយ-អដ្ឋកថា, បាចិត្តិយកណ្ឌំ)

**៤. អពីជំ** ផ្លែឈើដែលគ្មានគ្រាប់

**៥. និព្វត្តពីជំ** ផ្លែឈើដែលគេយកគ្រាប់ចេញ ។

## ១០.មេត្តាដើម្បីខ្លួន

**២៦. អនុជានាមិ ភិក្ខវេ ឥមានិ ចត្តារិ អហិរាជកុលានិ មេត្តេន ចិត្តេន ផរិតុំ, អត្តគុត្តិយា អត្តរក្ខាយ អត្តបរិត្តំ កាតុំ។ ឯវញ្ច បន ភិក្ខវេ កាតព្វំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឱ្យភិក្ខុផ្សាយមេត្តាចិត្តទៅកាន់ត្រកូលស្តេចពស់ទាំង ៤ នេះ ដើម្បីគ្រប់គ្រងខ្លួន ដើម្បីរក្សាខ្លួន ដើម្បីការពារខ្លួន ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវធ្វើមេត្តាចិត្តយ៉ាងនេះឯង ។

## ១១.ការកាត់អង្គជាត

**២៧. ន ភិក្ខវេ អត្តនោ អង្គជាតំ ឆេតព្វំ យោ ឆិន្ទេយ្យ អាបត្តិ ថុល្លច្ចយស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវកាត់ អង្គជាតរបស់ខ្លួនទេ ភិក្ខុណាកាត់ ត្រូវអាបត្តិថុល្លច្ច័យ ។

## ១២.បាត្រ ១១ យ៉ាងភិក្ខុមិនគួរប្រើប្រាស់

១. ទារុបត្តោ បាត្រឈើ
២. សោវណ្ណមយោ បត្តោ បាត្រធ្វើដោយមាស
៣. រូបិយមយោ បត្តោ បាត្រធ្វើដោយប្រាក់
៤. មណិមយោ បត្តោ បាត្រធ្វើដោយកែវមណី
៥. វេឡុរិយមយោ បត្តោ បាត្រធ្វើដោយកែវពិទូរ្យ
៦. ផលិកមយោ បត្តោ បាត្រធ្វើដោយកែវផលិក
៧. កំសមយោ បត្តោ បាត្រធ្វើដោយសំរិទ្ធិ
៨. កាចមយោ បត្តោ បាត្រធ្វើដោយកែវកញ្ចក់
៩. តិបុមយោ បត្តោ បាត្រធ្វើដោយសំណប៉ាហាំង
១០. សីសមយោ បត្តោ បាត្រធ្វើដោយសំណភក់
១១. តម្ពលោហមយោ បត្តោ បាត្រធ្វើដោយស្ពាន់ ។

## ១៣.ទ្រង់អនុញ្ញាតបាត្រ

២៨. អនុជានាមិ ភិក្ខវេ ទ្វេ បត្តេ អយោបត្តំ មត្តិកាបត្តំ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបាត្រ ២

យ៉ាង គឺ បាត្រដីម្យ៉ាង បាត្រដែកម្យ៉ាង ។

## ១៤.ទ្រង់អនុញ្ញាតជើងបាត្រ

២៩. **អនុជានាមិ ភិក្ខវេ បត្តមណ្ឌលំ** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតជើងបាត្រ ។

## ១៥.ជើងបាត្រ ៣ យ៉ាង

១. **តិបុមយំ** ជើងបាត្រធ្វើដោយសំណប៉ាហាំង

២. **សីសមយំ** ជើងបាត្រធ្វើដោយសំណភក់

៣. **បកតិមណ្ឌលំ** ជើងបាត្រប្រក្រតី ។

៣០. **អនុជានាមិ ភិក្ខវេ លិខិតុំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យក្រឡឹងបាន ។

៣១. **អនុជានាមិ ភិក្ខវេ មករទន្តកំ ឆិន្ទិតុំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុកាត់លួសនោះ ធ្វើជាក្បាច់ធ្មេញមករ ។

៣២. **ន ភិក្ខវេ ចិត្រានិ បត្តមណ្ឌលានិ ធារេតព្វានិ**

**រូបកិណ្ណានិ ភិត្តិកម្មកតានិ យោ ធារេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ បកតិមណ្ឌលំ ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ជើងបាត្រ ដ៏វិចិត្រ ឆ្លាក់ដេរដាសដោយរូបស្រី និងប្រុសជាដើម និងលាបឱ្យមានពណ៌ផ្សេងៗ ទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ, ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ជើងបាត្រប្រក្រតី ។

## ១៦.ការទុកដាក់បាត្រ

៣៣. **ន ភិក្ខវេ សោទកោ បត្តោ បដិសាមេតព្វោ យោ បដិសាមេយ្យ អាបត្តិ ទុក្កដស្ស ។ អនុជានាមិ ភិក្ខវេ ឱតាបេត្វា បត្តំ បដិសាមេតុំ ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទុកដាក់បាត្រទាំងទទឹកទេ ភិក្ខុណាទុកដាក់ ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឱ្យភិក្ខុហាលបាត្រសិន ហើយសឹមទុកដាក់ ។

៣៤. **ន ភិក្ខវេ សឧទកោ បត្តោ ឱតាបេតព្វោ យោ**

**ឱតាបេយ្យ អាបត្តិ ទុក្កដស្ស, អនុជានាមិ ភិក្ខវេ និរុទកំ កត្វា ឱតាបេត្វា បត្តំ បដិសាមេតុំ ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវហាលបាត្រទាំងទទឹកទេ ភិក្ខុណាហាល ត្រូវអាបត្តិទុក្កដ, ម្នាលភិក្ខុទាំងឡាយតថាគតអនុញ្ញាត ឱ្យភិក្ខុជូតបាត្រឱ្យស្ងួតទឹកសិន ហើយសឹមហាលទុក ដាក់ចុះ ។

៣៥. **ន ភិក្ខវេ ឧណ្ហេ បត្តោ និទហិតព្វោ យោ និទហេយ្យ អាបត្តិ ទុក្កដស្ស ។ អនុជានាមិ ភិក្ខវេ មុហុត្តំ ឧណ្ហេ ឱតាបេត្វា បត្តំ បដិសាមេតុំ ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទុកដាក់បាត្រក្នុងទីក្ដៅ ទេ ភិក្ខុណាទុក ត្រូវអាបត្តិទុក្កដ, ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឱ្យ ភិក្ខុហាលបាត្រក្នុងទីក្ដៅមួយរំពេច ហើយសឹមទុកដាក់ចុះ ។

៣៦. **អនុជានាមិ ភិក្ខវេ បត្តាធារកំ ។** ម្នាលភិក្ខុ ទាំងឡាយ តថាគតអនុញ្ញាតគ្រឿងរងតម្កល់បាត្រ ។

៣៧. **ន ភិក្ខវេ មិឍន្តេ បត្តោ និក្ខិបិតព្វោ យោ**

**និក្ខិបេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវដាក់បាត្រ លើទីបំផុតនៃផែនក្តារតាំងទេ ភិក្ខុណាដាក់ ត្រូវអាបត្តិទុក្កដ ។

៣៨. **ន ភិក្ខវេ បរិភណ្ឌន្តេ បត្តោ និក្ខិបិតព្វោ យោ និក្ខិបេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវដាក់បាត្រលើទីបំផុតនៃថ្នាក់ទេ ភិក្ខុណាដាក់ ត្រូវអាបត្តិទុក្កដ ។

## ១៧.ទ្រង់អនុញ្ញាតទីសម្រាប់ទុកបាត្រ

| | |
|---|---|
| **១.តិណសន្ថារកំ** | អនុញ្ញាតកម្រាលស្មៅ |
| **២.ចោឡកំ** | អនុញ្ញាតកំណាត់សំពត់ |
| **៣.បត្តមាឡកំ** | អនុញ្ញាតរោងសម្រាប់ទុកបាត្រ |
| **៤.បត្តកុណ្ឌោលិកំ** | អនុញ្ញាតភាជន៍ដី មានមាត់ធំ (ថ្លាង) សម្រាប់ទុកបាត្រ ។ |
| **៥.បត្តត្ថវិកំ** | អនុញ្ញាតថង់បាត្រ |

**៦.អំសវទ្ធកំ ពន្ធនសុត្តកំ** អនុញ្ញាតយោគបាត្រ និង

ខ្សែរសម្រាប់ចង ។

**៣៩. ន ភិក្ខវេ បត្តោ លគ្គេតព្វោ យោ លគ្គេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវព្យួរបាត្រទេ ភិក្ខុណាព្យួរ ត្រូវអាបត្តិទុក្កដ ។

**៤០. ន ភិក្ខវេ មញ្ចេ បត្តោ និក្ខិបិតព្វោ យោ និក្ខិបេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទុកបាត្រលើគ្រែទេ ភិក្ខុណាទុក ត្រូវអាបត្តិទុក្កដ ។

**៤១. ន ភិក្ខវេ បីឋេ បត្តោ និក្ខិបិតព្វោ យោ និក្ខិបេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទុកបាត្រលើតាំងទេ ភិក្ខុណាទុក ត្រូវអាបត្តិទុក្កដ។

**៤២. ន ភិក្ខវេ អង្កេ បត្តោ និក្ខិបិតព្វោ យោ និក្ខិបេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវដាក់បាត្រលើភ្លៅទាំងភ្នែនទេ ភិក្ខុណាដាក់ ត្រូវអាបត្តិទុក្កដ ។

៤៣. **ន ភិក្ខវេ ឆត្តេ បត្តោ និក្ខិបិតព្វោ យោ និក្ខិបេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវដាក់បាត្រក្នុងឆត្រទេ ភិក្ខុណាដាក់ ត្រូវអាបត្តិទុក្កដ ។

៤៤. **ន ភិក្ខវេ បត្តហត្ថេន ភិក្ខុនា កវាដំ បណាមេតព្វំ យោ បណាមេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានបាត្រនៅដៃមិនត្រូវច្រានសន្ទះទ្វារទេ ភិក្ខុណាច្រាន ត្រូវអាបត្តិទុក្កដ ។

៤៥. **ន ភិក្ខវេ តុម្ពកដាហេន បិណ្ឌាយ ចរិតព្វំ យោ ចរេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវដើរទៅបិណ្ឌបាត ដោយសម្បកឃ្លោកទេ ភិក្ខុណាដើរទៅ ត្រូវអាបត្តិទុក្កដ ។

៤៦. **ន ភិក្ខវេ ឃដិកដាហេន បិណ្ឌាយ ចរិតព្វំ យោ ចរេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវដើរទៅបិណ្ឌបាតដោយអម្បែងឆ្នាំងទេ ភិក្ខុណាដើរទៅ ត្រូវអាបត្តិទុក្កដ ។

**៤៧. ន ភិក្ខវេ ឆវសីសស្ស បត្តោ ធារេតព្វោ យោ ធារេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់បាត្រក្បាលខ្មោចទេ ភិក្ខុណាប្រើប្រាស់ត្រូវអាបត្តិទុក្កដ ។

**៤៨. ន ច ភិក្ខវេ សព្វបំសុកូលិកេន ភវិតព្វំ យោ ភវេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ម៉្យាងទៀត ភិក្ខុមិនត្រូវជាអ្នកប្រព្រឹត្តយកវត្ថុបំសុកូលគ្រប់មុខទេ ភិក្ខុណាប្រព្រឹត្តយក ត្រូវអាបត្តិទុក្កដ ។

## **១៨.កាកអាមិស**

**៤៩. ន ភិក្ខវេ ចលកានិ វា អដ្ឋិកានិ វា ឧច្ឆិដ្ឋោទកំ វា បត្តេន នីហរិតព្វំ យោ នីហរេយ្យ អាបត្តិ ទុក្កដស្ស។ អនុជានាមិ ភិក្ខវេ បដិគ្គហំ ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវ យកបាត្រដាក់កាកអាមិសដែលគេចោលក្តី ឆ្អឹងក្តី ទឹកជាដែលក្តី នាំយកទៅចោលទេ ភិក្ខុណានាំយកទៅចោលត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតកន្ថោរ ។

# ១៩.សំពត់តម្រងទឹក

៥០. **អនុជានាមិ ភិក្ខវេ បរិស្សាវនំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសំពត់តម្រងទឹក ។

៥១. **អនុជានាមិ ភិក្ខវេ កដច្ឆុបរិស្សាវនំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត សំពត់តម្រងទឹកដែលគេរឹតភ្ជាប់ឈើបីកំណាត់ ។

៥២. **អនុជានាមិ ភិក្ខវេ ធម្មករកំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតធម្មក្រក ។

៥៣. **ន ភិក្ខវេ អទ្ធានមគ្គប្បដិបន្នេន ភិក្ខុនា បរិស្សាវនំ យាចិយមានេន ន ទាតព្វំ យោ ន ទទេយ្យ អាបត្តិ ទុក្កដស្ស, ន ច ភិក្ខវេ អបរិស្សាវនកេន អទ្ធានមគ្គោ បដិបជ្ជិតព្វោ យោ បដិបជ្ជេយ្យ អាបត្តិ ទុក្កដស្ស សចេ ន ហោតិ បរិស្សាវនំ វា ធម្មករកោ វា សង្ឃាដិកណ្ណោបិ អធិដ្ឋាតព្វោ ឥមិនា បរិស្សាវេត្វា បិវិស្សាមិ ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ដើរទៅតាមផ្លូវឆ្ងាយ

កាលបើគេខ្វីតម្រងទឹក កុំគប្បីមិន ឱ្យ ភិក្ខុណាមិនឱ្យ ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀតភិក្ខុគ្មានសំពត់តម្រងទឹក មិនត្រូវដើរផ្លូវឆ្ងាយទេ ភិក្ខុណាដើរ ត្រូវអាបត្តិទុក្កដ, បើមិនមានសំពត់តម្រងទឹកក្តី ធម្មក្រកក្តី ទុកជាជាយសង្ឃាដី ក៏ត្រូវអធិដ្ឋានបានថា អាត្មាអញនឹងត្រងទឹក ដោយជាយសង្ឃាដីនេះឆាន់ ។

៥៤. **អនុជានាមិ ភិក្ខវេ ទណ្ឌបរិស្សាវនំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត សំពត់តម្រងទឹកមានដង ។

៥៥. **អនុជានាមិ ភិក្ខវេ ឱត្ថរិកំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសំពត់តម្រងទឹកត្រាំ ។

## ២០.អនុញ្ញាតមុង

៥៦. **អនុជានាមិ ភិក្ខវេ មកសកុដិកំ ។** ម្នាលភិក្ខុទាំង-ឡាយ តថាគតអនុញ្ញាតមុង ។

៥៧. **អនុជានាមិ ភិក្ខវេ ចង្កមញ្ច ជន្តាឃរញ្ចាតិ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទីចង្ក្រម និងរោងភ្លើង ។

## ២១.ភិក្ខុអាក្រាត

**៥៨. ន ភិក្ខវេ នគ្គេន នគ្គោ អភិវាទេតព្វោ, ន នគ្គេន អភិវាទេតព្វំ, ន នគ្គេន នគ្គោ អភិវាទាបេតព្វោ, ន នគ្គេន អភិវាទាបេតព្វំ, ន នគ្គេន នគ្គស្ស បរិកម្មំ កាតព្វំ,ន នគ្គេន បរិកម្មំ ការាបេតព្វំ, ន នគ្គេន នគ្គស្ស ទាតព្វំ, ន នគ្គេន បដិគ្គហេតព្វំ, ន នគ្គេន ខាទិតព្វំ, ន នគ្គេន ភុញ្ជិតព្វំ, ន នគ្គេន សាយិតព្វំ, ន នគ្គេន បាតព្វំ យោ បិវេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាក្រាត មិនត្រូវសំពះភិក្ខុអាក្រាត, ភិក្ខុអាក្រាត មិនត្រូវ សំពះភិក្ខុ (គេ), ភិក្ខុអាក្រាត មិនត្រូវឱ្យគេសំពះភិក្ខុអាក្រាត, ភិក្ខុអាក្រាត មិនត្រូវឱ្យគេសំពះខ្លួន, ភិក្ខុអាក្រាតមិនត្រូវធ្វើបរិកម្មដល់ភិក្ខុអាក្រាត, ភិក្ខុអាក្រាតមិនត្រូវឱ្យគេធ្វើបរិកម្មដល់ខ្លួន, ភិក្ខុអាក្រាតមិនត្រូវឱ្យរបស់, ភិក្ខុអាក្រាតមិនត្រូវទទួលរបស់, ភិក្ខុអាក្រាត មិនត្រូវទំពាស៊ី,

ភិក្ខុអាក្រាត មិនត្រូវបរិភោគ, ភិក្ខុអាក្រាតមិនត្រូវលិទ្ធភ្លក្ស, ភិក្ខុអាក្រាតមិនត្រូវផឹកទេ, ភិក្ខុណាផឹក ត្រូវអាបត្តិទុក្កដ ។

## ២២.ទីបិទបាំង ៣ យ៉ាង

៥៩. **អនុជានាមិ ភិក្ខវេ តិស្សោ បដិច្ឆាទិយោ ជន្តាឃរបដិច្ឆាទឹ, ឧទកបដិច្ឆាទឹ, វត្ថបដិច្ឆាទឹ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទីបិទបាំង ៣ យ៉ាង គឺ ទីបិទបាំងដោយរោងភ្លើង ១, ទីបិទបាំងដោយទឹក ១, ទីបិទបាំងដោយសំពត់ ១ ។

## ២៣.និសីទនៈជាដើម

៦០. **ន ភិក្ខវេ ចាតុម្មាសំ និសីទនេន វិប្បវសិតព្វំ យោ វិប្បវសេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវនៅប្រាសចាកនិសីទនៈអស់ ៤ ខែទេ ភិក្ខុណានៅប្រាស ត្រូវអាបត្តិទុក្កដ ។

**៦១. ន ភិក្ខវេ បុប្ផាភិកិណ្ណេសុ សយនេសុ សយិតព្វំ យោ សយេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវដេកលើដំណេក ដែលគេរោយរាយដោយផ្កាឈើទេ ភិក្ខុណាដេក ត្រូវអាបត្តិទុក្កដ ។

**៦២. អនុជានាមិ ភិក្ខវេ គន្ធំ គហេត្វា កវាដេ បញ្ចង្គុលិកំ ទាតុំ បុប្ផំ គហេត្វា វិហារេ ឯកមន្តំ និក្ខិបិតុំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យទទួល គ្រឿងក្រអូប ហើយឱ្យប្រោះព្រំដោយម្រាមដៃ ៥ ត្រង់ទ្វារនិងបង្អួច ព្រមទាំងទទួលយកផ្កាទៅទុកក្នុងទីដ៏សមគួរក្នុងវិហារបាន ។

**៦៣. អនុជានាមិ ភិក្ខវេ នមតកំ ។** ម្នាលភិក្ខុ-ទាំងឡាយ តថាគតអនុញ្ញាតកម្រាលស្នាច់ ដែលគេធ្វើដោយរោមចៀម ។

**៦៤. ន ភិក្ខវេ នមតកំ អធិដ្ឋាតព្វំ ន វិកប្បេតព្វំ ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនបាច់អធិដ្ឋាន មិនបាច់វិកប្បនូវកម្រាលស្នាច់ដែលគេធ្វើដោយរោមចៀមទេ ។

## ២៤.ភាជន៍ពិសេសជាដើម

**៦៥. ន ភិក្ខវេ អាសិត្តកុបធានេ ភុញ្ជិតព្វំ យោ ភុញ្ជេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុ មិនត្រូវឆាន់ភោជនក្នុងភាជន៍ពិសេសសម្រាប់រងចង្ហាន់ទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ ។

**៦៦. អនុជានាមិ ភិក្ខវេ មឡោរិកំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតភាជន៍សម្រាប់រងដែលធ្វើដោយឈើ ។

## ២៥.ឯកភាជនេជាដើម

**៦៧. ន ភិក្ខវេ ឯកភាជនេ ភុញ្ជិតព្វំ, ន ឯកថាលកេ បាតព្វំ, ន ឯកមញ្ចេ តុវដ្ដិតព្វំ, ន ឯកត្ថរណេ តុវដ្ដិតព្វំ, ន ឯកបាវុរណេ តុវដ្ដិតព្វំ, ន ឯកត្ថរណបាវុរណេ តុវដ្ដិតព្វំ យោ តុវដ្ដេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់ (ភោជន) រួមភាជន៍ជាមួយគ្នា, មិនត្រូវផឹកទឹករួមផ្តិលជាមួយគ្នា, មិនត្រូវដេកលើគ្រែជាមួយគ្នា,

មិនត្រូវដេកលើកម្រាលជាមួយគ្នា, មិនត្រូវដេកដណ្តប់ជាមួយគ្នា, មិនត្រូវដេកលើកម្រាល និងដណ្តប់ជាមួយគ្នាទេ ភិក្ខុណាដេក ត្រូវអាបត្តិទុក្កដ ។

## ២៦.ការផ្កាប់បាត្រដល់វឌ្ឍលិច្ឆវី

**៦៨. អដ្ឋហិ ភិក្ខវេ អង្គេហិ សមន្នាគតស្ស ឧបាសកស្ស បត្តោ និក្កុជ្ជិតព្វោ ភិក្ខូនំ អលាភាយ បរិសក្កតិ ភិក្ខូនំ អនត្ថាយ បរិសក្កតិ ភិក្ខូនំ អានាវាសាយ បរិសក្កតិ ភិក្ខូ អក្កោសតិ បរិភាសតិ ភិក្ខូ ភិក្ខូហិ ភេទេតិ ពុទ្ធស្ស អវណ្ណំ ភាសតិ ធម្មស្ស អវណ្ណំ ភាសតិ សង្ឃស្ស អវណ្ណំ ភាសតិ ។**

ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវផ្កាប់បាត្រដល់ឧបាសកដែលប្រកបដោយអង្គ ៨ ប្រការ គឺឧបាសកព្យាយាមដើម្បីនឹងមិនឱ្យភិក្ខុទាំងឡាយបានលាភ ១, ព្យាយាមដើម្បីនឹងមិនឱ្យភិក្ខុទាំងឡាយបានប្រយោជន៍ ១, ព្យាយាមដើម្បីនឹងមិនឱ្យភិក្ខុទាំងឡាយបានទីលំនៅ ១, ជេរប្រទេច

ពួកភិក្ខុ ១, បំបែកពួកភិក្ខុឱ្យបែកចាកពួកភិក្ខុ ១, ពោលតិះដៀលព្រះពុទ្ធ ១, ពោលតិះដៀលព្រះធម៌ ១, ពោលតិះដៀលព្រះសង្ឃ ១ ។

**៦៩.អដ្ឋហិ, ភិក្ខវេ, អង្គេហិ សមន្នាគតស្ស ឧបាសកស្ស បត្តោ ឧក្កុជ្ជិតព្វោ  ន  ភិក្ខូនំ  អលាភាយ បរិសក្កតិ, ន ភិក្ខូនំ អនត្ថាយ បរិសក្កតិ, ន ភិក្ខូនំ អវាសាយ បរិសក្កតិ, ន ភិក្ខូ អក្កោសតិ បរិភាសតិ, ន ភិក្ខូ ភិក្ខូហិ ភេទេតិ, ន ពុទ្ធស្ស អវណ្ណំ ភាសតិ, ន ធម្មស្ស អវណ្ណំ ភាសតិ, ន សង្ឃស្ស អវណ្ណំ ភាសតិ ។**

ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវផ្ងារបាត្រដល់ឧបាសកដែលប្រកបដោយអង្គ ៨ ប្រការ  គឺឧបាសកមិនព្យាយាមដើម្បីនឹងមិនឱ្យភិក្ខុទាំងឡាយបានលាភ ១, មិនព្យាយាមដើម្បីនឹងមិនឱ្យភិក្ខុទាំងឡាយបានប្រយោជន៍ ១, មិនព្យាយាមដើម្បីនឹងមិនឱ្យភិក្ខុទាំងឡាយបានទីលំនៅ ១,

មិនជេរប្រទេចពួកភិក្ខុ ១, មិនញុះញង់ភិក្ខុទាំងឡាយឱ្យបែកចាកភិក្ខុទាំងឡាយ ១, មិនពោលតិះដៀលព្រះពុទ្ធ ១, មិនពោលតិះដៀលព្រះធម៌ ១, មិនពោលតិះដៀលព្រះសង្ឃ ១ ។

## ២៧.កម្រាលនិងទ្រនាប់សម្រាប់ជូតជើង

៧០. **ន ភិក្ខវេ ចេឡបដិកា អក្កមិតព្វា យោ អក្កមេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវជាន់កម្រាលសំពត់ទេ ភិក្ខុណាជាន់ ត្រូវអាបត្តិទុក្កដ ។

៧១. **អនុជានាមិ ភិក្ខវេ គិហីនំ មង្គលត្ថាយ យាចិយមានេន ចេឡបដិកំ អក្កមិតុំ ។** ម្នាលភិក្ខុទាំង-ឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុដែលគ្រហស្ថអង្វរ ដើម្បីប្រយោជន៍ជាមង្គលជាន់កម្រាលសំពត់បាន ។

**៧១. អនុជានាមិ ភិក្ខវេ គិហីនំ មង្គលត្ថាយ យាចិយមានេន ចេឡបដិកំ អក្កមិតុំ ។** ម្នាលភិក្ខុទាំង-ឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុដែលគ្រហស្ថអង្វរ ដើម្បីប្រយោជន៍ជាមង្គលជាន់កម្រាលសំពត់បាន ។

**៧២. អនុជានាមិ ភិក្ខវេ ធោតបាទកំ អក្កមិតុំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុជាន់លើកម្រាលសម្រាប់ភិក្ខុមានជើងស្អាតបាន ។

**៧៣. អនុជានាមិ ភិក្ខវេ ឃដកញ្ច សម្មជ្ជនិញ្ច ។ ន ភិក្ខវេ កតកំ បរិភុញ្ជិតព្វំ យោ បរិភុញ្ជេយ្យ អាបត្តិ ទុក្កដស្ស ។ អនុជានាមិ ភិក្ខវេ តិស្សោ បាទឃំសនិយោ សក្ខរំ កឋលំ សមុទ្ទផេណកំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតក្អម និងអំបោស ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ទ្រនាប់សម្រាប់ជូតជើង មានរចនាដូចពកផ្លែឈូកទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។

ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ទ្រនាប់សម្រាប់ជូតជើង ៣ យ៉ាង គឺ ក្រួស ឬដុំថ្ម ១ អង្កែបក្បឿង ឬឥដ្ឋ ១ ផ្សិតដែលកើតពីពពុះទឹកសមុទ្រ ១ ។

## ២៨.ផ្លិត

**៧៤. អនុជានាមិ ភិក្ខវេ វិធូបនញ្ច តាលវណ្ដញ្ច ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតផ្លិតបួនជ្រុង និងផ្លិតមូល (ផ្លិតស្លឹកត្នោត) ។

**៧៥. អនុជានាមិ ភិក្ខវេ មកសវីជនី ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតផ្លិតសម្រាប់បក់មូស ។

**៧៦. ន ភិក្ខវេ ចាមរីវីជនី ធារេតព្វា យោ ធារេយ្យ អាបត្តិ ទុក្កដស្ស ។ អនុជានាមិ ភិក្ខវេ តិស្សោ វីជនិយោ វាកមយំ ឧសីរមយំ មោរបិញ្ឆមយំ ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ផ្លិតដែលគេធ្វើដោយរោមចាមរីទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតផ្លិត ៣ យ៉ាង គឺ

ផ្ចិតដែលគេធ្វើដោយសម្បកឈើ១, ផ្ចិតដែលគេក្រងដោយស្បូវភ្លាំង១, ផ្ចិតដែលគេធ្វើដោយរោមកន្ទុយក្ងោក ១ ។

## ២៩.ឆត្រ

៧៧. **អនុជានាមិ ភិក្ខវេ ឆត្តំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឆត្រ ។

៧៨. **ន ភិក្ខវេ ឆត្តំ ធារេតព្វំ យោ ធារេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ឆត្រទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។

៧៩. **អនុជានាមិ ភិក្ខវេ គិលានស្ស ឆត្តំ ។** ម្នាលភិក្ខុ-ទាំងឡាយ តថាគតអនុញ្ញាតឆត្រដល់ភិក្ខុមានជម្ងឺ។

៨០. **អនុជានាមិ ភិក្ខវេ អគិលានេនបិ ភិក្ខុនា អារា-មេ អារាមុបចារេ ឆត្តំ ធារេតុំ ។** ម្នាលភិក្ខុទាំងឡាយ តថាគត ឱ្យភិក្ខុមិនមានជម្ងឺបាំងឆត្រក្នុងអារាម និង ឧបចារៈនៃអារាមបាន ។

## ៣០.ឈើច្រត់ជាដើម

**៨១. ន ភិក្ខវេ ទណ្ឌសិក្កា ធារេតព្វា យោ ធារេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ឈើច្រត់ទាំងសង្រែកទេ ភិក្ខុណាប្រើប្រាស់ត្រូវអាបត្តិទុក្កដ ។

**៨២. អនុជានាមិ ភិក្ខវេ គិលានស្ស ភិក្ខុនោ ទណ្ឌសមតឹ ទាតុំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យសង្ឃឱ្យទណ្ឌសម្មតិ ដល់ភិក្ខុមានជម្ងឺ ។

**៨៣. អនុជានាមិ ភិក្ខវេ គិលានស្ស ភិក្ខុនោ សិក្កាសម្មតឹ ទាតុំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យសង្ឃឱ្យសិក្កាសម្មតិដល់ភិក្ខុមានជម្ងឺ ។

**៨៤. អនុជានាមិ ភិក្ខវេ គិលានស្ស ភិក្ខុនោ ទណ្ឌសិក្កាសម្មតឹ ទាតុំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឱ្យសង្ឃឱ្យទណ្ឌសិក្កាសម្មតិដល់ភិក្ខុមានជម្ងឺ។

## ៣១.ភិក្ខុអ្នកទំពាអៀង

**៨៥. អនុជានាមិ ភិក្ខវេ រោមដ្ឋកស្ស រោមដ្ឋំ ន ច ភិក្ខវេ ពហិមុខទ្វារំ នីហរិត្វា អជ្ឈោហរិតព្វំ យោ អជ្ឈោហរេយ្យ យថាធម្មោ ការេតព្វោ ។**

ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទំពាអៀង ដល់ភិក្ខុអ្នកទំពាអៀងជាប្រក្រតី, ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែភិក្ខុកុំខ្ជាក់អាហារ ចេញមកខាងក្រៅទ្វាមាត់ហើយ លេបចូលទៅវិញ បើភិក្ខុណាលេបចូលទៅវិញវិន័យធម៌ គប្បី ឱ្យភិក្ខុនោះធ្វើតាមធម៌ (សំដែងអាបត្តិចេញ) ។

## ៣២.ការរើសគ្រាប់បាយ

**៨៦. អនុជានាមិ ភិក្ខវេ យំ ទិយ្យមានំ បតតិ តំ សាមំ គហេត្វា បរិភុញ្ជិតុំ តំ កិស្ស ហេតុ បរិច្ចត្តំ តំ ភិក្ខវេ ទាយកេហីតិ ។** ម្នាលភិក្ខុទាំងឡាយ គ្រាប់បាយណា ដែលគេកំពុងឱ្យហើយធ្លាក់ចុះ តថាគតអនុញ្ញាតឱ្យភិក្ខុ រើសគ្រាប់បាយនោះខ្លួនឯង ហើយឆាន់ចុះ ព្រោះហេតុអ្វី

ម្នាលភិក្ខុទាំងឡាយ ព្រោះថាគ្រាប់បាយនោះ ទាយក គេលះ គឺប្រគេនរួចស្រេចហើយ ។

## ៣៣.មិនត្រូវទុកក្រចកវែង

**៨៧. ន ភិក្ខវេ ទីឃា នខា ធារេតព្វា យោ ធារេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុ មិនត្រូវទុកក្រចកវែងទេ ភិក្ខុណាទុកត្រូវអាបត្តិទុក្កដ ។

**៨៨. អនុជានាមិ ភិក្ខវេ នខច្ឆេទនំ ។** ម្នាលភិក្ខុ ទាំងឡាយ តថាគតអនុញ្ញាតឱ្យកាត់ក្រចក ។

**៨៩. អនុជានាមិ ភិក្ខវេ មំសប្បមាណេន នខំ ឆិន្ទិតុំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុ កាត់ក្រចកត្រឹមនឹងសាច់ ។

**៩០. ន ភិក្ខវេ វីសតិមដ្ឋំ ការាបេតព្វំ យោ ការាបេយ្យ អាបត្តិ ទុក្កដស្ស, អនុជានាមិ ភិក្ខវេ មលមត្តំ អបកឌ្ឍិតុំ ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឱ្យគេខាត់ ក្រចកទាំង ២០ ទេ ភិក្ខុណាឱ្យខាត់ ត្រូវអាបត្តិទុក្កដ,

ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុគ្រាន់តែជម្រុះក្អែលប៉ុណ្ណោះ។

## ៣៩.មិនត្រូវឱ្យគេកាត់ពុកមាត់-សក់

**៩១. ន ភិក្ខវេ មស្សុ កប្បាបេតព្វំ ន មស្សុ វឌ្ឍាបេតព្វំ ន គោលោមិកំ ការាបេតព្វំ ន ចតុរស្សកំ ការាបេតព្វំ ន បរិមុខំ ការាបេតព្វំ ន អឌ្ឍរុកំ ការាបេតព្វំ ន ទាឋិកា ឋបេតព្វា ន សម្ពាធេ លោមំ សំហរាបេតព្វំ យោ សំហរាបេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឱ្យគេកាត់ពុកមាត់ (ដោយកន្ត្រៃ) មិនត្រូវទុកពុកមាត់ឱ្យវែង មិនត្រូវឱ្យគេធ្វើពុកចង្កាឱ្យវែង (ដូចជាពុកចង្កាពពែ) មិនត្រូវឱ្យគេធ្វើពុកមាត់ ៤ ជ្រុង មិនត្រូវប្រមូលជួររោមត្រង់ទ្រូង មិនត្រូវធ្វើជួររោមត្រង់ពោះ មិនត្រូវទុកពុកមាត់ឱ្យដូចជាចង្កូម មិនត្រូវឱ្យគេដករោមក្នុងទីចង្អៀត ភិក្ខុណាឱ្យគេដក ត្រូវអាបត្តិទុក្កដ ។

**៩២. អនុជានាមិ ភិក្ខវេ អាពាធប្បច្ចយា សម្ពាធេ លោមំ សំហរាបេតុំ ។** ម្នាលភិក្ខុទាំងឡាយ (បើ) មានអាពាធជាហេតុ តថាគតអនុញ្ញាតឱ្យភិក្ខុឱ្យគេជករោមក្នុងទីចង្អៀតបាន ។

**៩៣. ន ភិក្ខវេ កត្តរិកាយ កេសា ឆេទាបេតព្វា យោ ឆេទាបេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវកាត់សក់ដោយកន្ត្រៃទេ ភិក្ខុណាឱ្យគេកាត់ ត្រូវអាបត្តិទុក្កដ ។

**៩៤. អនុជានាមិ ភិក្ខវេ អាពាធប្បច្ចយា កត្តរិកាយ កេសេ ឆេទាបេតុំ ។** ម្នាលភិក្ខុទាំងឡាយ បើមានអាពាធជាហេតុ តថាគតអនុញ្ញាតឱ្យភិក្ខុឱ្យគេកាត់សក់ដោយកន្ត្រៃបាន ។

**៩៥. ន ភិក្ខវេ ទីឃំ នាសិកាលោមំ ធារេតព្វំ យោ ធារេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទុករោមច្រមុះឱ្យវែងទេ ភិក្ខុណាទុកត្រូវអាបត្តិទុក្កដ ។

**៩៦. អនុជានាមិ ភិក្ខវេ សណ្ឌាសំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសណ្ឌាស ។

**៩៧. ន ភិក្ខវេ បលិតំ គាហាបេតព្វំ យោ គាហាបេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុ មិនត្រូវឱ្យគេដកសក់ស្កូវទេ ភិក្ខុណាឱ្យគេដក ត្រូវអាបត្តិទុក្កដ ។

## ៣៥.ចង្កៀលអាចម៍ត្រចៀកជាដើម

**៩៨. អនុជានាមិ ភិក្ខវេ កណ្ណមលហរណឹ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតចង្កៀលអាចម៍ត្រចៀក ។

**៩៩. ន ភិក្ខវេ ឧច្ចាវចា កណ្ណមលហរណិយោ ធារេតព្វា យោ ធារេយ្យ អាបត្តិ ទុក្កដស្ស, អនុជានាមិ ភិក្ខវេ កណ្ណមលហរណិយោ អដ្ឋិមយំ ទន្តមយំ វិសាណមយំ នឡមយំ វេឡុ មយំ កដ្ឋមយំ ជតុមយំ ផលមយំ លោហមយំ សង្ខនាភិមយំ ។** ម្នាលភិក្ខុទាំងឡាយ

ភិក្ខុមិនត្រូវ ប្រើប្រាស់ចង្កៀលអាចម៍ត្រចៀកខ្ពស់ និង ទាប(មិនរាបសា)ទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ, ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ចង្កៀលអាចម៍ត្រចៀកដែលធ្វើដោយឆ្អឹង ភ្លុក ស្នែង បបុស ឫស្សី ឈើជ័រឈើ ផ្លែឈើ លោហជាតិ គូថស័ង្ខ ។

១០០. **ន ភិក្ខវេ លោហភណ្ឌំ កំសភណ្ឌំ សន្និចយោ កាតព្វោ យោ ករេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវសន្សំទុកដាក់គ្រឿងលោហជាតិ និងគ្រឿងសំរិទ្ធទេ ភិក្ខុណាសន្សំទុកដាក់ ត្រូវអាបត្តិទុក្កដ ។

១០១. **ន ភិក្ខវេ សង្ឃាដិបល្លត្ថិកាយ និសីទិតព្វំ យោ និសីទេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវអង្គុយត្របោមក្បាលជង្គង់ទាំងសង្ឃាដិទេ ភិក្ខុណាអង្គុយ ត្រូវអាបត្តិទុក្កដ ។

១០២. **អនុជានាមិ ភិក្ខវេ អាយោគំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសំពត់អាយោគ ។

**១០៣. អនុជានាមិ ភិក្ខវេ តន្តកំ វេមំ កវដំ សលាកំ សព្វំ តន្តភណ្ឌកំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតក្តារម្ងរធ្មេញឈើ ខ្សែរសម្រាប់រឹតចន្ទាស់ និងប្រដាប់ត្បាញទាំងអស់ ។

## ៣៦.កាយពន្ធ

**១០៤. ន ភិក្ខវេ អកាយពន្ធនេន គាមោ បវិសិ-តព្វោ យោ បវិសេយ្យ អាបត្តិ ទុក្កដស្ស, អនុជានាមិ ភិក្ខវេ កាយពន្ធនំ ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនមានកាយពន្ធ មិនត្រូវចូលទៅកាន់ស្រុកទេ ភិក្ខុណាចូលទៅ ត្រូវអាបត្តិទុក្កដ, ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតកាយពន្ធ ។

**១០៥. ន ភិក្ខវេ ឧច្ចាវចានិ កាយពន្ធនានិ ធា-រេតព្វានិ កលាពុកំ ទេឌ្ឍុភកំ មុរជ្ជំ មទ្ទវិណំ យោ ធារេយ្យ អាបត្តិ ទុក្កដស្ស, អនុជានាមិ ភិក្ខវេ ទ្វេ កាយពន្ធនានិ បដ្តិកំ សូករទន្តកំ ។**

ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់កាយពន្ធខ្ពស់ និង ទាប (មិនរាបសា) គឺកាយពន្ធមានខ្សែច្រើន កាយពន្ធមានសណ្ឋានដូចក្បាលពស់ទឹក កាយពន្ធមានសណ្ឋានដូចខ្សែរឹតសំភោរ និង កាយពន្ធមានសណ្ឋានដូចសង្វារទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ,ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតកាយពន្ធ ២ យ៉ាង គឺកាយពន្ធធ្វើជាផ្ទាំង១, កាយពន្ធមានសណ្ឋានដូចពោះវៀនជ្រូក១ ។

**១០៦. អនុជានាមិ ភិក្ខវេ មុរជំ មទ្ទវីណំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតជាយកាយពន្ធមានសណ្ឋាន ដូចខ្សែរឹតសម្ភោរ និងជាយកាយពន្ធមានសណ្ឋានដូចសង្វារ ។

**១០៧. អនុជានាមិ ភិក្ខវេ សោភកំ គណកំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតដេរលិន និងដេរឱ្យមានអាការៈដូចផ្លែស្គួយ ។

**១០៨. អនុជានាមិ ភិក្ខវេ វិធំ ។** ម្នាលភិក្ខុទាំងឡាយ

តថាគតអនុញ្ញាតក្រវិលកាយពន្ធ ។

**១០៩. ន ភិក្ខវេ ឧច្ចាវចា វិថា ធារេតព្វា យោ ធារេយ្យ អាបត្តិ ទុក្កដស្ស, អនុជានាមិ ភិក្ខវេ វិថេ អដ្ឋិមយំ ទន្តមយំ វិសាណមយំ នឡមយំ វេឡុមយំ កដ្ឋមយំ ជតុមយំ ផលមយំ លោហមយំ សង្ខនាភិមយំ សុត្តមយំ ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ក្រវិលកាយពន្ធខ្ពស់ និងទាបទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ, ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតក្រ-វិលកាយពន្ធដែលធ្វើដោយឆ្អឹង ដោយភ្លុក ដោយបបុស ដោយឫស្សី ដោយឈើ ដោយជ័រ ដោយផ្លែឈើ ដោយលោហជាតិ ដោយគូថស័ង្ខ ធ្វើដោយសូត្រ ឬអំបោះ ។

## ៣៧.ឡេវនិងអន្ទាក់ឡេវចីវរ

**១១០. អនុជានាមិ ភិក្ខវេ គណ្ឋិកំ បាសកំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឡេវ និងអន្ទាក់ឡេវ (សង្ឃាដិ និង ឧត្តរាសង្គៈ) ។

**១១១. ន ភិក្ខវេ ឧច្ចាវចា គណ្ឋិកា ធារេតព្វា**

**យោ ធារេយ្យ អាបត្តិ ទុក្កដស្ស, អនុជានាមិ ភិក្ខវេ គណ្ឋិកំ អដ្ឋិមយំ ទន្តមយំ វិសាណមយំ នឡមយំ វេឡុមយំ កដ្ឋមយំ ជតុមយំ ផលមយំ លោហមយំ សង្ខនាភិមយំ សុត្តមយំ ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ឡេវខ្ពស់ និងទាបទេ ភិក្ខុណា ប្រើប្រាស់ ត្រូវអាបត្តិទុក្កដ, ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឡេវដែលធ្វើដោយឆ្អឹង ដោយភ្លុក ដោយបបុស ដោយឫស្សី ដោយឈើ ដោយជ័រ ដោយផ្លែឈើ ដោយលោហជាតិ ដោយគូថស័ង្ខ ធ្វើដោយសូត្រ ឬអំបោះ ។

១១២. **អនុជានាមិ ភិក្ខវេ គណ្ឋិកផលកំ បាសកផលកំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ទ្រនាប់ឡេវ និងទ្រនាប់អន្ទាក់ឡេវ ។

១១៣. **អនុជានាមិ ភិក្ខវេ គណ្ឋិកផលកំ អន្តេអប្បេតុំ បាសកផលកំ សត្តង្គុលំ វា អដ្ឋង្គុលំ វា ឱគាហេត្វា អប្បេតុំ ។** ម្នាលភិក្ខុទាំងឡាយ តថាគត

អនុញ្ញាតឱ្យភិក្ខុដេរភ្ជាប់ទ្រនាប់ឡេវក្នុងទីបំផុតចីវរ ដេរទ្រនាប់អន្ទាក់បន្តយចូលមកខាងក្នុងត្រឹម ៧ ផ្ទាប់ ឬ ៨ ផ្ទាប់ ។

## ៣៨.ភិក្ខុមិនត្រូវស្លៀកនិងដណ្តប់ដូចគ្រហស្ថ

១. ហត្ថិសោណ្ឌិកំ ស្លៀកឱ្យស្លុយមុខដូចប្រមោយដំរី
២. មច្ឆវាឡកំ មានសណ្ឋានដូចកន្ទុយត្រី
៣. ចតុក្កណ្ណកំ ស្លៀកឱ្យមានជ្រុង ៤
៤. តាលវណ្ដកំ ស្លៀកមានអាការដូចធាងត្នោត
៥. សតវល្លិកំ ស្លៀកអង្កាញ់ឱ្យមានផ្នត់ច្រើន
៦. សំវល្លិយំ ស្លៀកចងក្បិន ។

**១១៤. ន ភិក្ខវេ គិហិបារុតំ បារុបិតព្វំ យោ បារុបេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវដណ្តប់ដូចគ្រហស្ថទេ ភិក្ខុណាដណ្តប់ត្រូវអាបត្តិទុក្កដ ។

**១១៥. ន ភិក្ខវេ សំវល្លិយំ និវាសេតព្វំ យោ**

**និវាសេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវស្លៀកចងក្បិនទេ ភិក្ខុណាស្លៀក ត្រូវអាបត្តិទុក្កដ។

## ៣៩.ភិក្ខុមិនត្រូវនាំអម្រែកទេ

**១១៦. ន ភិក្ខវេ ឧភតោកាជំ ហរិតព្វំ យោ ហរេយ្យ អាបត្តិ ទុក្កដស្ស, អនុជានាមិ ភិក្ខវេ ឯកតោកាជំ អន្តរាកាជំ សីសភារំ ខន្ធភារំ កដិភារំ ឱលម្ពកំ ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវនាំអង្រែកទេ ភិក្ខុណានាំទៅ ត្រូវអាបត្តិទុក្កដ, ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឱ្យភិក្ខុពុន សែង ទូល លី កណ្ដៀត និងយួរបាន ។

## ៤០.ឈើស្ទន់

ទោសក្នុងការមិនទំពាឈើស្ទន់មាន ៥ ប្រការ

**១. អចក្ខុស្សំ** នាំឱ្យថយកម្លាំងភ្នែក

២. **មុខំ ទុគ្គន្ធំ ហោតិ** មាត់មានក្លិនស្អុយ

៣. **រសហរណិយោ ន វិសុជ្ឈន្តិ** សសៃសម្រាប់នាំរសមិនបរិសុទ្ធ ។

៤. **បិត្តំបិ សេម្ហំបិ ភត្តំ បរិយោនទ្ធតិ** ប្រមាត់ និងស្លេសរួបរឹតបាយ ។

៥. **ភត្តមស្ស ន ឆាទេតិ** ភិក្ខុនោះឆាន់ចង្ហាន់មិនឆ្ងាញ់ ។

អានិសង្សក្នុងការទំពារឈើស្ទន់មាន ៥ ប្រការ

គឺនាំឱ្យមានកម្លាំងភ្នែក១, មាត់មិនមានក្លិនស្អុយ១, សសៃសម្រាប់នាំរសបរិសុទ្ធ១, ប្រមាត់និងស្លេសមិនរួបរឹតបាយ១, ភិក្ខុនោះឆាន់ចង្ហាន់ឆ្ងាញ់១ ។

១១៧. **ន ភិក្ខវេ ទីឃំ ទន្តកដ្ឋំ ខាទិតព្វំ យោ ខាទេយ្យ អាបត្តិ ទុក្កដស្ស, អនុជានាមិ ភិក្ខវេ អដ្ឋង្គុលបរមំ ទន្តកដ្ឋំ ន ច តេនេវ សាមណេរោ អា-កោដេតព្វោ យោ អាកោដេយ្យ អាបត្តិ ទុក្កដស្ស ។**

ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទំពាឈើស្ទន់វែងទេ

ភិក្ខុណាទំពា ត្រូវអាបត្តិទុក្កដ, ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឈើស្ទន់យ៉ាងវែងត្រឹម ៨ ធ្នាប់ តែថាកុំគោះវាយសាមណេរដោយឈើស្ទន់នោះឡើយ ភិក្ខុណាគោះ ត្រូវអាបត្តិទុក្កដ ។

**១១៨. ន ភិក្ខវេ អតិមន្ទហកំ ទន្តកដ្ឋំ ខាទិតព្វំ យោ ខាទេយ្យ អាបត្តិ ទុក្កដស្ស, អនុជានាមិ ភិក្ខវេ ចតុរង្គុលំ បច្ឆិមំ ទន្តកដ្ឋំ ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទំពាឈើស្ទន់ខ្លីពេកទេ ភិក្ខុណាទំពា ត្រូវអាបត្តិទុក្កដ, ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឈើស្ទន់ យ៉ាងខ្លីបំផុតត្រឹម ៤ ធ្នាប់ ។

## ៤១.ភិក្ខុដុតព្រៃ

**១១៩. ន ភិក្ខវេ ទាយោ អាឡេបេតព្វោ យោ អាឡេបេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវដុតព្រៃទេ ភិក្ខុណាដុត ត្រូវអាបត្តិទុក្កដ ។

**១២០. អនុជានាមិ ភិក្ខវេ ទវឌាហេ ឧឃ្ជមានេ**

**បដគ្គិ ទាតុំ បរិត្តំ កាតុំ ។** ម្នាលភិក្ខុទាំងឡាយ កាលបើភ្លើងព្រៃឆេះមក តថាគតអនុញ្ញាតឱ្យដុតភ្លើងតទល់ ដើម្បីនឹងធ្វើសេចក្ដីការពារបាន ។

## ៤២.ការឡើងដើមឈើ

**១២១. ន ភិក្ខវេ រុក្ខោ អភិរូហិតព្វោ យោ អភិរូ-ហេយ្យអាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឡើងដើមឈើទេ ភិក្ខុណាឡើង ត្រូវអាបត្តិទុក្កដ ។

**១២២. អនុជានាមិ ភិក្ខវេ សតិ ករណីយេ បោរិសិយំ រុក្ខំ អភិរូហិតុំ អាបទាសុ យាវទត្ថំ ។** ម្នាលភិក្ខុទាំងឡាយ កាលបើមានកិច្ចគួរធ្វើ តថាគតអនុញ្ញាត ឱ្យឡើងដើមឈើបានត្រឹមមួយជួរបុរស បើមានអន្តរាយ ឱ្យឡើងកំណត់ត្រឹមណាក៏បាន ។

## ៤៣.រៀនពុទ្ធវចនៈតាមសកភាសា

**១២៣. ន ភិក្ខវេ ពុទ្ធវចនំ ឆន្ទសោ អារោបេតព្វំ**

**យោ អារោបេយ្យ អាបត្តិ ទុក្កដស្ស, អនុជានាមិ ភិក្ខវេ សកាយ និរុត្តិយា ពុទ្ធវចនំ បរិយាបុណិតុំ ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវលើ ពុទ្ធវចនតាមឆន្ទទេ ភិក្ខុណាលើក ត្រូវអាបត្តិទុក្កដ, ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឱ្យភិក្ខុរៀនពុទ្ធវចនៈតាមសកភាសា គឺមគធភាសា ។

## ៥៥.លោកាយតៈ

១២៤. **ន ភិក្ខវេ លោកាយតំ បរិយាបុណិតព្វំ យោ បរិយាបុណេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវរៀនគម្ពីរលោកាយតៈទេ ភិក្ខុណារៀន ត្រូវអាបត្តិទុក្កដ ។

១២៥. **ន ភិក្ខវេ លោកាយតំ វាចេតព្វំ យោ វាចេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវបង្រៀនគម្ពីរលោកាយតៈទេ ភិក្ខុណាបង្រៀន ត្រូវអាបត្តិទុក្កដ ។

**១២៦. ន ភិក្ខវេ តិរច្ឆានវិជ្ជា បរិយាបុណិតព្វា យោ បរិយាបុណេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវរៀនតិរច្ឆានវិជ្ជាទេ ភិក្ខុណារៀន ត្រូវអាបត្តិទុក្កដ ។

**១២៧. ន ភិក្ខវេ តិរច្ឆានវិជ្ជា វាចេតព្វា យោ វាចេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវបង្រៀនតិរច្ឆានវិជ្ជាទេ ភិក្ខុណាបង្រៀន ត្រូវអាបត្តិទុក្កដ ។

## ៤៥.កណ្ដាស

**១២៨. ន ភិក្ខវេ ខិបិតេ ជីវាតិ វត្តព្វោ យោ វទេយ្យ អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ អ្នកដទៃ ភិក្ខុមិនត្រូវពោលថា "អ្នកចូររស់នៅក្នុងវេលាកណ្ដាស" (ប៉ុណ្ណោះ) ទេ ភិក្ខុណាពោល ត្រូវអាបត្តិទុក្កដ ។

**១២៩. គិហី ភិក្ខវេ មង្គលិកា, អនុជានាមិ ភិក្ខវេ គិហីនំ ជីវថ ភន្តេតិ វុច្ចមានេន ចិរំ ជីវាតិ វត្តុន្តិ ។**

ម្នាលភិក្ខុទាំងឡាយ ធម្មតាគ្រហស្ថទាំងឡាយ ត្រូវការដោយមង្គល, ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុដែលគ្រហស្ថនិយាយថា "បពិត្រលោកដ៏ចម្រើនលោកចូររស់នៅ" ដូច្នេះ ឱ្យនិយាយតបវិញថា "អ្នកចូររស់នៅអស់កាលយូរ" ដូច្នេះបាន ។

១៣០. **ន ភិក្ខវេ លសុណំ ខាទិតព្វំ យោ ខាទេយ្យ អាបត្តិ ទុក្កដស្ស** ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់ខ្ទឹមទេ ភិក្ខុណាឆាន់ត្រូវអាបត្តិទុក្កដ ។

១៣១. **អនុជានាមិ ភិក្ខវេ អាពាធប្បច្ចយា លសុណំ ខាទិតុំ** ។ ម្នាលភិក្ខុទាំងឡាយ បើមានអាពាធជាហេតុ តថាគតអនុញ្ញាតឱ្យភិក្ខុឆាន់ខ្ទឹមបាន ។

## ៤៦.ការបន្ទោបង់បស្សាវៈ និងវច្ចៈ

១៣២. **អនុជានាមិ ភិក្ខវេ ឯកមន្តំ បស្សាវំ កាតុំ** ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុបន្ទោបង់បស្សាវៈតែក្នុងកន្លែងមួយ ។

១៣៣. **អនុជានាមិ ភិក្ខវេ បស្សាវកុម្ភី ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឆ្នាំងសម្រាប់រងបស្សាវៈ ។

១៣៤. **អនុជានាមិ ភិក្ខវេ បស្សាវបាទុកំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទ្រនាប់ជើងសម្រាប់បន្ទោបង់បស្សាវៈ ។

១៣៥. **អនុជានាមិ ភិក្ខវេ បរិក្ខិបិតុំ តយោ បាការេ ឥដ្ឋកាបាការំ សិលាបាការំ ទារុបាការំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបិទបាំងដោយកំពែង ៣ យ៉ាង គឺកំពែងឥដ្ឋ១, កំពែងថ្ម១, កំពែងឈើ១ (សម្រាប់បន្ទោបង់បស្សាវៈ) ។

១៣៦. **អនុជានាមិ ភិក្ខវេ អបិធានំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគម្រប ។

១៣៧. **អនុជានាមិ ភិក្ខវេ ឯកមន្តំ វច្ចំ កាតុំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុបន្ទោបង់វច្ចៈតែក្នុងកន្លែងមួយ ។

១៣៨. **អនុជានាមិ ភិក្ខវេ វច្ចកូបំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតរណ្តៅវច្ចៈ ។

១៣៩. **អនុជានាមិ ភិក្ខវេ ចិនិតុំ តយោ ចយេ, ឥដ្ឋកាចយំ សិលាចយំ ទារុចយំ ។** ម្នាលភិក្ខុ ទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុកខឿន ៣ យ៉ាង គឺខឿនឥដ្ឋ១, ខឿនថ្ម១, ខឿនឈើ១ (សម្រាប់បន្ទោបង់វច្ចៈ) ។

១៤០. **អនុជានាមិ ភិក្ខវេ ឧច្ចវត្ថុកំ កាតុំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុធ្វើទីដីឱ្យខ្ពស់ឡើង ។

១៤១. **អនុជានាមិ ភិក្ខវេ វច្ចកុដឹ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតវច្ចកុដិ ។

១៤២. **ន ភិក្ខវេ វិវិធំ អនាចារំ អាចរិតព្វំ យោ អាចរេយ្យ យថាធម្មោ ការេតព្វោ ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រព្រឹត្តអនាចារផ្សេងៗ ទេ ភិក្ខុណាប្រព្រឹត្ត វិន័យធរគប្បីឱ្យភិក្ខុនោះធ្វើតាមធម៌ ។

១៤៣. **អនុជានាមិ ភិក្ខវេ ឋបេត្វា បហរណឹ**

**សព្វំ លោហភណ្ឌំ, ឋបេត្វា អាសន្ទឹ បល្លង្កំ ទារុបត្តំ ទារុបាទុកំ សព្វំ ទារុភណ្ឌំ, ឋបេត្វា កតកញ្ច កុម្ភការិកញ្ច សព្វំ មត្តិកាភណ្ឌន្តិ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគ្រឿងលោហៈទាំងពួង វៀរលែងតែលោហៈដែលជាគ្រឿងសម្រាប់ប្រហារ, អនុញ្ញាតគ្រែទាំងពួង វៀរលែងតែអាសនៈកន្លងហួសប្រមាណ ដែលហៅថា **អាសន្ទិ**, អនុញ្ញាតគ្រឿងឈើទាំងពួង វៀរលែងតែបាត្រឈើ និងទ្រនាប់ជើងឈើ, អនុញ្ញាតគ្រឿងដីទាំងពួង វៀរលែងតែគ្រឿងជូតជើងដែលគេធ្វើជាពកឱ្យស្រួចៗ ឡើង មានអាការដូចពកគ្រាប់ផ្លែឈូក និងកុដិធ្វើដោយដីសុទ្ធ (ដូចកុដិធនិយភិក្ខុ) ។

# ខុទ្ទកវត្ថុខន្ធកំ និដ្ឋិតំ

## ចប់ ខុទ្ទកវត្ថុខន្ធកៈ

**បា បា ម ចុ បី តិ បញ្ច**

**វិធំ វិនយបិដកំ**

**វណ្ណនាស្យបទុតច**

**បសមន្តទ្ឋយាកមា ៥**

វិន័យបិដកមាន ៥ ប្រការគឺ បារាជិកកណ្ឌ ១, បាចិត្តិយកណ្ឌ ១, មហាវគ្គ ១, ចូឡវគ្គ ១, បរិវារៈ ១ វណ្ណនា គឺអដ្ឋកថានៃវិន័យបិដកនោះ មាន ៥ ប្រការ តាមលំដាប់គឺ បឋមសមន្ត ១, ទុតិយសមន្ត ១, តតិយសមន្ត ១, ចតុត្ថសមន្ត ១, បញ្ចសមន្ត ១ ។

(គម្ពីរវជិរសារ)